# ពន្យល់ពាក្យខ្លះ

## ជាសំដីខ្មែរ ហើយ ជីវតាក្វាន់ កត់ជាអក្សរចិន (រៀបតាមលំដាប់អក្សរ)

កាងពាងឈ្វ រឺ កាងពាងជ្វ : តាមយោបល់របស់លោក ប៉េលិយោតថា ពាក្យកាងពាង ក្លាយពីពាក្យកំពង់ ។ តាមយោបល់របស់យើងថា កំពង់ចិន សរសេរតែមួយមាត់ទេថា ប៉ុង ដូចជាប៉ុងចាំ : កំពង់ចាម។ ម្យ៉ាងទៀត ឈ្វ រឺ ជ្វ ប្រែមិនកើត ។ ដូច្នេះ យើងយល់ថាពាក្យនេះទំនងជាមកពីពាក្យ កំពែងជួរ ទៅវិញ ព្រោះពីដើមទីក្រុងនិមួយៗ តោងធ្វើជាកំពែងជាជួរព័ទ្ធជុំវិញ ជាព្រំដែននៃទីក្រុង។ ក្នុងបរិវេណនៃកំពែងនេះ អ្នកក្នុងរស់នៅ មានវាំង មានផ្សារផ្សៅ មានផ្ទះអ្នកទីក្រុង។ ទំលាប់បុរាណហៅថាកំពែង រឺ សីមា។ សូមមើលពាក្យលោក សុត្តន្តប្រីជាអិន្ទ ក្នុងគតិលោកទី១ និយាយហៅទីក្រុងថា កំពែង។ នៅសិលាចារឹកជាច្រើនក៏ហៅទីក្រុងថា កំពែង។ លោកប៉េលិយោត បានប្រែកាងពាងជ្វថា Vill Murée ក៏សមន័យថាកំពែងនេះដែរ។

កានពូជី (ចិនទាជីវអាន : កាំព័រទី) : ជាសំដីចិន កត់តាមសំដីខ្មែរ : កម្ពុជ រឺ កម្ពុជា។ ហេតុនេះហើយ បានជាចិនដែលសរសេរក្រោយជីវតាក្វាន់កែទៅជា កាំពូចេ ដែលនៅប្រើជាប់រហូតសព្វថ្ងៃនេះ។ ជីវតាក្វាន់ បានបញ្ជាក់ក្នុងសេចក្ដីផ្ដើមថា តាមការកត់ត្រារបស់ពួកអឺរ៉ុបថា ប្រទេសនេះឈ្មោះដូច្នេះដែរ។ ត្រង់នេះនាំអោយយើងដឹងថា ជីវតាក្វាន់ បានមើលសៀវភៅកំនត់ហេតុរបស់អឺរ៉ុប គឺពួកព័រទុយហ្គេ ដែលសរសេរឈ្មោះប្រទេសយើងថា Kambuja រឺ Kamvuja កម្វុជ (សូមមើលសៀវភៅ Le Cambodge។

យុនលុន : ឈ្មោះសមុទ្រ ដែលលោកជីវតាក្វាន់និយាយថា នៅតាមរយៈផ្លូវពីក្រុងចាម មកស្រុកចេនលា។ លោក ប៉េលិយោតស្រាជ្រាវឃើញថា ជាសមុទ្រកោះត្រលាច ដែលលោកប្រែ = Lamer de Poulo-Condor ប៉ុន្តែយើងស្រាវជ្រាវតាមរកអោយឃើញន័យច្បាស់ជាងនេះទៀតពុំទាន់ឃើញ។

ចេនគាឡាង រឺ តាំងកេលាង : ទំនងជាពាក្យសំស្ក្រឹត ស្រីគារដែលខ្មែរនិយមយកមកប្រើ ហៅពពួក ស្នំបរិវារ និង អ្នកបំរើស្ដេច សំរាប់ហែហម ជាលំអនិង កត្តិយសស្ដេច។ យើងសរសេរសព្វថ្ងៃទៅជា «ស្រឹង្គារ»។ មកពីដំបូងគេអានថា សឹងគារ: មានសំលេង រ: នៅចុងលុះចិនគ្មានអក្សរ រ ក៏យកសំលេង ឡ រឺ ល មកជំនួសបានជា សីការ: ទៅជា ចេន គា ឡាង។

ចេងផូវ រឺ ថេងភូ : លោកជីវតាក្វាន់ ទុកជាឈ្មោះស្រុកមួយ ជាជាយដែនប្រទេសចេនលា។ លោកប៉េលិយោតបញ្ជាក់ថែមថា ស្រុកនេះនៅត្រង់ភូមិភាគ Cap Saint-Jacques រឺ ខេត្តបារៀសព្វថ្ងៃនេះ។

ចេនលា រឺ ចេនលាក់ : ពាក្យនេះនៅក្នុងការរាវរកសំខាន់ណាស់ ព្រោះជាឈ្មោះប្រទេសតែម្ដង។ នឹងថា ជាឈ្មោះដែលអ្នកស្រុកយើងហៅខ្លួនថា យើងជាអ្នកចេនលា រឺ ជាតិចេនលា ក៏មិនមែន ព្រោះដូចនិយាយខាងដើមសេចក្ដីប្រែនេះស្រាប់ ដែលលោកជីវតាក្វាន់បញ្ជាក់ អ្នកប្រទេសនេះហៅខ្លួនអែងថា កាន់ ដៃ ចី ហើយដែលអ្នកស្រុកអឺរ៉ុបកត់ទុកថា កាំពូចី ដែលមានសំលេងស្រដៀងនឹង កាំពូចេ ដែរ។ កំនត់នេះបង្ហាញថា មិនមែនជនជាតិយើងដាក់ ឈ្មោះចេនលានេះទេ ប្រាកដជាបរទេសហៅសំគាល់តាមហេតុ រឺ តាមរបស់អ្វីមួយមិនខាន ពិសេសគឺចិននេះអែង បានមកទាក់ទងហើយបានសរសេរកត់ត្រាស្រុកយើងមុនគេ (តាំងពីសតវត្សទី៤) ។ បើដូច្នេះយើងត្រូវរាវរកតាមសំនៀងសំដីចិន តើ

ចេនលានេះថាត្រាប់តាមសំដីខ្មែរថាម៉េច? អុទាហរណ៍ ពាក្យ ហ្វូហាន រឺ ហ្វូណាម មកពីត្រាប់ពាក្យខ្មែរថា ភ្នំ ចិនគ្មានអក្សរតំរួត ម្លោះហើយ ភ្នំ រំលែកសំលេងទៅជាភូណម រឺ ភូណាម។

កាលខ្ញុំទៅស្រុកចិន ជួបនឹងអ្នកស្រាវជ្រាវចចិនម្នាក់ ឈ្មោះស៊ីរម៉េង គាត់ប្រាប់ខ្ញុំថា គាត់ឃើញអែកសារមួយនិយាយពីឈ្មោះចេនលានេះ។ គឺដើមឡើយ ចិនហៅប្រទេសមួយ ដែលស្ថិតនៅខាងលើ ប្រទេសហ្វូណាន។ ប្រទេសនោះមានព្រៃក្រាស់ណាស់ ហើយសំបូរឃ្មុំយកក្រមួនធ្វើទៀន។ ពួកចិនតែងធ្វើដំនើរតាមសំពៅមកទិញដូរយកក្រមួនសុទ្ធ គឺក្រមួនយកពីឃ្មុំ ដើម្បីនាំទៅលក់អែស្រុកគេ សំរាប់ធ្វើទៀន ហើយគេនាំគ្នាសន្មតហៅស្រុកនេះថា : ក្រមួនសុទ្ធៗ គឺថា ចេន រឺ ចេង ប្រែថាសុទ្ធ អែឡា រឺឡាក់ ប្រែថា ក្រមួន រឺ ឃ្មុំ រឺ ទៀន (ភាសាចិនគេដាក់គុណនាមមុននាម) បូករួមមកបានន័យថា «ស្រុកក្រមួនសុទ្ធ»។ មានយោបល់មួយទៀតចុះសំរុងគ្នាថា នៅច្រកទន្លេធ្លាយទៅសមុទ្រ ជាកន្លែងអ្នកចេនលា នាំក្រមួនសុទ្ធទៅទុកលក់អោយសំពៅចិននោះ គេសន្មតឈ្មោះស្រុកក្រមួនដែរ គឺក្រមួនស (កម្ពុជាក្រោម) សនេះមិនសំដៅខ្លាញ់គោទេ ព្រោះសម័យនោះមិនទាន់មាន ដូច្នោះ សនេះគឺ ជាសុទ្ធនេះអែង ហើយនៅភូមិភាគក្រមួនសនេះ ក៏មានស្រុកភូមិមានឈ្មោះថា ក្រមួនៗច្រើនណាស់ នាំអោយសន្និដ្ឋានបានថា : ស្រុកភូមិត្រង់នោះជាទីឃ្លាំងផ្ទុកក្រមួន នាំទៅទុកលក់អោយសំពៅចិនមែន ព្រោះសំពៅដើរតែតាមសមុទ្រ មិនបានចូលមកតាមទន្លេទេ។

ឆីនថា រឺ ឆេនថាន់ : ទំនងមកពីពាក្យ ជាន់ឋាន ក្រែងក្នុងពិធីនេះគេនាំលោកមកកាន់ទីកន្លែងរបស់កូនស្រី? ប៉ុន្តែក្នុងទំនៀម ហើយមកអិលូវនេះមិនឃើញមានធ្វើដូច្នេះទេ។ ពត៌មាននេះ មិនគួរនឹងជឿ ប៉ុន្តែយើងយល់ថា តើលោកជីវតាក្វាន់បំផ្លើសរឿងនេះដើម្បីប្រយោជន៍អ្វី? មិនតែប៉ុណ្ណោះ លោកបញ្ជាក់ទាំងពេលដែលឃើញគេធ្វើ ហើយត្រង់ណាលោកមិនឃើញផ្ទាល់ភ្នែកដូចជានៅក្នុបន្ទាប់ក៏លោកបញ្ជាក់ច្បាស់ថា លោកគ្រាន់តែលឺគេថាទេ (ត្រង់នេះឃើញថាលោកមានចិត្តត្រង់ណាស់ក្នុងដំនើរកត់ហេតុនេះ។

ឆេណាំ រឺ ឆាណាំ : ជាសំលេងចិន ត្រាប់តាមពាក្យខ្មែរឆ្នាំង ដោយសារចិនគ្មានសំលេងអក្សរតំរួត គឺសំដៅយក កំពង់ឆ្នាំង ព្រោះពាក្យកំពង់ប្រែថា ភូមិ ម្លោះហើយ លោកជីវតាក្វាន់កត់យកតែឈ្មោះភូមិតែម្តង។ ច្បាស់ថែមពីលើនេះទៀត គឺ លោកជីវតាក្វាន់បានរាប់រៀបថា ជាឈ្មោះខេត្តមួយនៃប្រទេសចេនលា ហើយគេធ្វើដំនើរចេញពីនេះ ត្រូវឆ្លងកាត់សមុទ្រសាប (ទន្លេសាប) អស់ពេលដប់ថ្ងៃទៀត ទើបដល់ក្រុងធំ។

ផូគូ : ក្លាយតាមសំដីចិន ទំនងជាហៅពាក្យខ្មែរ ចៅគូ ដែលគេធ្លាប់និយមប្រើនៅចុងសតវត្សទី១៣ សំរាប់ហៅលោកសង្ឃ (សព្វថ្ងៃសៀមនៅប្រើនៅឡើយ)។

ប៉ាតេង : ពាក្យខ្មែរបុរាណ ម្រតេង ដែលក្រោយមកក្លាយជា កំរតេង រួចសព្វថ្ងៃថា គំដែង គឺសំរាប់សំគាល់ងារមន្ត្រីជាន់ខ្ពស់ និង អ្នប្រាជ្ញធំ រឺ អ្នកមានរិទ្ធតេជៈខ្លាំងក្លា។ សព្វថ្ងៃនៅប្រើចំពោះព្រះសង្ឃ អុទាហរណ៍ : បពិត ព្រះគំដែងសង្ឃ ទាំងឡាយ ជាដើម។

ប៉ាធ : ទំនងជាត្រប់តាមសំលេងអ្នកស្រុកដើមហៅថា ប៉ាតូវ។ លោកប៉ែលិយោត បញ្ជាក់ថា សព្វថ្ងៃជានជាតិចារាយនៅប្រើពាក្យ ប៉ាតូវ ហៅអូវពុកនៅឡើយ។

ប៉ានឃាប រឺ ប៉ានឃីត : ទំនងជាត្រាប់សំលេងខ្មែរ បណ្ឌិត (ដែលយើងអានក្លាយទៅ បន្ទិត រឺ អន្ទិត សំដៅយកពួកអ្នកប្រាជ្ញ។

ប៉ាវទៀងកាក : តាមសេចក្តីក្នុងអត្ថបទ លោកជីវតាក្វាន់ ហៅសំគាល់អង្គរ។ មកពីពាក្យអង្គរ បុរាណយើង ហៅវង្គរ

មានប្រើក្នុងសិលាចារឹកជាច្រើន។

ប៉ាស៊ីវ៉ី : សំស្រ្កឹត បស្វី ប្រែថាអ្នកមានតបៈ គឺខ្មែរបុរាណហៅពពួកអ្នកបួសជាតាបសនៅតាមព្រៃ ច្រើនអ្នកប្រតិបត្តិតាមគម្ពីរវេទ (សូមមើលក្នុងរឿងរាមកេរខ្មែរ គេប្រើពាក្យនេះសំរាប់ពួកយក្សហៅព្រះរាម ដែលធ្វើតបៈក្នុងព្រៃថា បស្វី។

ផេង កេស៊ី : លោកជីវតាក្វាន់ថា ផេងកេស៊ី ជារុក្ខជាតិដែលគេយកស្លឹកវាមកធ្វើស្រា។ យើងបានប្រទះឃើញក្នុងវចនានុក្រមខ្មែរភាគ១ ទំព័រ ៨២៩ និយាយថា ខ្មែរយើងជាន់ដើមគេយកស្លឹកឈើម្យ៉ាងមកធ្វើស្រា ហៅថា ស្លឹកភ្វាស។ ភ្វាសនេះជាឈើព្រៃ មានសំបកក្រមរជ្រួញៗ ស្លឹកល្អិតរឹង ផ្កាល្អិតកញ្ចុំ ពណ៌ស្វាយ។ ដូច្នេះគឺស្លឹកភ្វាស នេះហើយ ដែលកត់តាមសំលេងចិនទៅជាផេកេស៊ី។

ពុទ្ឡៃ : សំស្រ្កឹត ព្រះ ប្រែថា ប្រសើរ គឺតាមនិយមន័យខ្មែរសំរាប់ហៅបុគ្គលជាទីគោរព មានព្រះពុទ្ធអង្គជាដើម ។ ក្រោយមកគេហៅមន្រ្តីមានសក្តិខ្ពស់ រឺ សង្ឃដែលមានសមណសក្តិ។

ពូលូវ រឺ ពូលូឈិង មកពីពាក្យផ្លូវ ដែលចិនគ្មានសំលេងអក្សរតំរួត ក៏អានទៅជាពីរព្យាង្គថា ពូលូវ ។អែពាក្យឈិង ជាពាក្យចិនប្រែថា ភូមិ ដូច្នេះ ពាក្យនេះមានន័យថា ភូមិផ្លូវ ទំនងជា «ភូមិផ្លូវត្រី សព្វថ្ងៃទេដឹង? ព្រោះអត្ថបទនេះ និយាយពីភូមិនៅមាត់ទន្លេសាប តាមរយៈដំនើរទៅសៀមរាប។

ភុយឡាំង : លោកប៉េលិយោត លោកពន្យល់ពាក្យនេះថា C'est le non d'une barque faite seule pièce de bois, l'original plan? piran n'est pas cnnu ចំពោះយើង យល់ថា ទំនងជាទូកកំរោល ដែលគេលុងធ្វើពីឈើមួយដើម ប៉ុន្តែមិនដឹងជាឈ្មោះដើមថាម៉េច បានជាចិនកត់ជាពាក្យហៅផុយឡាំងនេះ។

ម៉ែ រឺ មី :ជាពាក្យសំរាប់មនុស្សស្ត្រី រឺ សំរាប់ហៅម្តាយដែលចិនខំថាតាមសំលេងខ្មែរមេ។ អុទាហរណ៍ មេជ្រូក មេគោ មេបា...។

សាមប៉ា : ចិនអានតាមសំលេងខ្មែរថា សំពះ។

ស៊ុនណា : លោក ប៉េលិយោត ដាក់ក្នុងវង់ក្រចកអានថា Siennaja ហើយលោកពន្យល់ន័យថា L'original de ce nom de bateau, quelque chose comme senda, n'a pas éteé retrouvé តាមមតិយើង គឺជាទូកម្យ៉ាង ដែលគេយកបន្ទះក្តារមកវាយភ្ជាប់ភ្ជិតគ្នា គេច្រើនហៅសព្វថ្ងៃថា ទូកឡើងក្តារ បុរាណហៅថាទូកសន្តរ។ ទំនងជា សន្តរ នេះហើយ ដែលចិនកត់ទៅជាស៊ីនណា។

ស៊ីលាក់ទី : មកពីពាក្យសំស្រ្កឹត ស្រិស្និន រឺ ស្រិស្វី ប្រែថា អ្នកទ្រទ្រង់ នូវស្រុតិ គឺពួកអ្នកចេះដឹង រឺ អ្នកមានប្រាជ្ញា។

ហ៊ុតឈឹង : ពាក្យនេះ មកពីភាសាចិន : ហ៊ុត = ព្រះពុទ្ធ + ឈឹង = ភូមិព្រះពុទ្ធ។ លោក ប៉េលិយោត យល់ថាជាភូមិពោធិសាត់ ប៉ុន្តែ បើតាមកំនាព្យលោកសុតន្តប្រីជាអិន្ទ និរាសអង្គរវត្ត លោកនិយាយដំនើរលោកទៅអង្គរវត្តតាមមាត់ទន្លេសាប ឃើញភូមិមួយនៅពាក់កន្តាលផ្លូវនេះឈ្មោះថា ភូមិត្រភព។ ហើយគាត់ពិចារណាថា នរណាយកពាក្យត្រៃភពមកដាក់ឈ្មោះ ជានាមរបស់ព្រះពុទ្ធដែរ ដូច្នេះហ៊ុឈឹង គឺជាភូមិត្រៃភពនោះអែង។

Website : www.khmercenter.ch មណ្ឌលវប្បធម៌ខ្មែរនៅប្រទេសស្វីស
ជាសេវាកម្ម ក្នុងការផ្សាយពុទ្ធសាសនា វប្បធម៌ ជាភាសាខ្មែរ

Khmer Culture Center in Switzerland,
Phone (41)44 3635900 , Fax (41)44 3635900
© 2004 The Switzerland Buddhist Society, (watkhmer) Inc. All rightsreserved.